# មេរៀនទី ២៦: ព្រះអង្គគឺជាតួនៃសេចក្តីស្រឡាញ់

## ១ កូរិនថូស ១៣:១-១៣

**គោលបំណង៖** ព្រះអង្គគឺជាតួនៃសេចក្ដីស្រឡាញ់។

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៣:៣៤** *“ខ្ញុំឲ្យសេចក្ដីបញ្ញត្ត១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

សូមអាន **១កូរិនថូស១:១៣**ម្តងទៀត ហើយសរសេរអំពីរបៀបដែលប៉ុលបានពិពណ៌នាអំពីសេចក្តីស្រឡាញ់។ គូសរង្វង់ពាក្យដែលអ្នកគិតថា វាពិពណ៌នាអំពីគុណភាពនៃសេចក្តីស្រឡាញ់របស់អ្នក។ ដាក់ផ្កាយមួយនៅជាប់នឹងលក្ខណៈណាមួយ ដែលអ្នកចង់បានជំនួយពីព្រះយេស៊ូវ ដើម្បីអភិវឌ្ឍនៅក្នុងជីវិតរបស់អ្នក។ តើជីវិតរបស់អ្នកអាចប្រែប្រួលយ៉ាងណា ប្រសិនបើអ្នកអាចស្រឡាញ់ដោយគ្រប់លក្ខណ៍? តើជីវិតអ្នកដ៏ទៃនឹងផ្លាស់ប្តូរយ៉ាងដូចម្តេច? ចូរអធិស្ឋានហើយសុំព្រះយេស៊ូវ ដើម្បីកែលម្អគុណភាពនៃសេចក្តីស្រឡាញ់របស់អ្នក។

**ចំរៀង៖** ១. ក្តីស្រលាញ់នៃព្រះផ្អែមហើយអស្ចារ្យ ២. ព្រះយេស៊ូវស្រលាញ់កុមារណាស់ ៣. ខ្ញុំឲ្យបញ្ញត្តិមួយថ្មី

### ១. អធិស្ឋាន *(សូមនាំកុមារអធិស្ឋានបើក)*

### ២. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ខ្ញុំស្រលាញ់...»

១. ឱ្យកុមារអង្គុយជារង្វង់។ (បើមានកៅអីសម្រាប់ឲ្យពួកគេអង្គុយកាន់តែប្រសើរ)



២. ជ្រើសរើសកុមារម្នាក់ធ្វើជាអ្នកដឹកនាំ ហើយឈរនៅកណ្តាលរង្វង់។

៣.កុមារនេះនឹងនិយាយថា “ខ្ញុំស្រឡាញ់ កុមារដែល______” (ឧទាហរណ៍៖ “ខ្ញុំស្រឡាញ់កុមារដែលមានសក់វែង” ឬ “ខ្ញុំ ស្រឡាញ់កុមារដែលស្លៀកខោខ្លី” ឬ “ខ្ញុំស្រឡាញ់កុមារដែល ពាក់វ៉ែនតា”) កុមារណាដែលត្រូវនឹងការពិពណ៌នា ត្រូវតែក្រោកចេញពីកៅអី ហើយប្តូរទៅអង្គុយកន្លែងផ្សេងទៀត។ កុមារដែលជាអ្នកដឹកនាំត្រូវអង្គុយយ៉ាងលឿននៅពេលកុមារណាម្នាក់ក្រោកឡើង។

៤. កុមារណាដែលមិនអាចរកកៅអីថ្មីអង្គុយបាននឹងក្លាយជាអ្នកដឹកនាំបន្ទាប់ ហើយនិយាយថា “ខ្ញុំស្រឡាញ់កុមារដែល _____”។

### ៤. ការណែនាំមេរៀន

តើប្អូនស្រឡាញ់អ្វីនៅក្នុងជីវិតរបស់ប្អូន? តើប្អូនស្រឡាញ់ម្ហូបអាហារដែរទេ? តើប្អូនស្រឡាញ់ប្រដាប់ក្មេងលេងទេ? តើប្អូនស្រឡាញ់អំណោយដែលគេឲ្យដែរទេ? នៅពេលប្អូនស្រលាញ់អ្វីមួយ ប្អូនចង់រក្សាវាឱ្យនៅជិតប្អូនជានិច្ច។ ឧទាហរណ៍៖ បើប្អូនស្រលាញ់របស់លេង នោះប្អូនចង់ទុករបស់លេងនោះនៅជិតប្អូន។ ឬបើប្អូនចូលចិត្ត

ញ៉ាំអាហារ ប្អូនតែងតែចង់មានអាហារញ៉ាំជានិច្ច។ ឬប្រសិនបើប្អូនស្រឡាញ់នរណាម្នាក់ (ដូចជាម៉ាក់ឬប៉ារបស់ប្អូន) នោះ ប្អូនចង់ឱ្យពួកគេនៅក្បែរប្អូនរហូត។

ព្រះបានបង្កើតប្អូន ហើយទ្រង់ស្រឡាញ់ប្អូន។ ហើយដោយព្រោះព្រះស្រឡាញ់ប្អូន ស្រឡាញ់ខ្ញុំ ហើយនឹងអ្នកដទៃទៀតនោះហើយ ទើបព្រះអង្គចង់ឲ្យយើងនៅក្បែរទ្រង់។ វិធីមួយដែលបង្ហាញថា យើងមានទំនាក់ទំនងជិតស្និទ្ធនឹងព្រះគឺដោយការបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះចំពោះគ្នាទៅវិញទៅមក។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងព្រះគម្ពីរមានជំពូកមួយដែលគេស្គាល់ថាជាជំពូកដែលនិយាយពីសេចក្តីស្រឡាញ់។ គឺនៅក្នុង **១កូរិនថូស ១៣** ទាំងមូលនិយាយអំពីសេចក្តីស្រឡាញ់។ ខ ៤ និង ៥ ចែងថា “ឯសេចក្ដីស្រឡាញ់ តែងតែអត់ធ្មត់ ហើយក៏សប្បុរស សេចក្ដីស្រឡាញ់មិនចេះឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំផង មិនដែលប្រព្រឹត្តបែបមិនគួរសមមិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស”។ វ៉ូវ! សេចក្តីស្រឡាញ់គឺពិតជាអស្ចារ្យណាស់!

សេចក្តីស្រឡាញ់គឺសំខាន់ណាស់ចំពោះព្រះ។ ព្រះយេស៊ូវមានបន្ទូលថាសេចក្តីស្រឡាញ់ត្រូវតែសំខាន់ សម្រាប់យើងរាល់គ្នាផងដែរ។ ព្រះយេស៊ូវមានព្រះបន្ទូលនៅក្នុង **យ៉ូហាន ១៣:៣៤** “ខ្ញុំឲ្យសេចក្ដីបញ្ញត្តិ១ថ្មីដល់អ្នករាល់គ្នាគឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ”។ វាមិនងាយស្រួលគ្រប់ពេលនោះទេ! ពេលខ្លះយើងត្រូវសុំព្រះយេស៊ូវឲ្យជួយយើង ឲ្យស្រឡាញ់មនុស្សដែលយើងមិនចូលចិត្ត។ ខ្ញុំសប្បាយចិត្តណាស់ដែលព្រះបានប្រទាននូវគម្ពីរ ដល់យើងដើម្បីជាជំនួយជួយយើងឲ្យចេះមានក្តីស្រឡាញ់។

ព្រះចង់ឲ្យយើងមករកទ្រង់ ដើម្បីទ្រង់អាចបំពេញយើងដោយសេចក្តីស្រឡាញ់របស់ទ្រង់។ បើទោះបីជាយើងបានធ្វើខុសក៏ដោយ យើងអាចទៅរកព្រះដើម្បីសុំការអភ័យទោស ហើយទទួលបាននូវសេចក្តីស្រឡាញ់ពីទ្រង់បានដែរ ។ ហេតុនេះហើយបានជាព្រះអង្គចាត់ព្រះរាជបុត្រាទ្រង់ឲ្យ មកសុគតជំនួសអំពើបាបរបស់យើង ហើយទ្រង់មានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូវស្រឡាញ់យើងហើយបានសុគតសម្រាប់យើងរាល់គ្នា ដើម្បីឲ្យយើងបាននៅជាមួយទ្រង់ជារៀងរហូត។ នេះហើយជាក្តីស្រឡាញ់ដ៏ពិត! ព្រះបានបង្កើតក្តីស្រឡាញ់ពិត ព្រះស្រឡាញ់យើង ព្រះទ្រង់ជាគួនៃសេចក្តីស្រឡាញ់ ហើយព្រះចង់ឲ្យយើងស្រឡាញ់អ្នកដទៃផងដែរ។ ព្រះអង្គចង់ឲ្យអ្នកដទៃដឹងថាទ្រង់ជាព្រះមានលក្ខណៈបែបណាតាមរយៈការស្រឡាញ់របស់យើងមានចំពោះពួកគេ។ ពេលយើងប្រព្រឹត្តដោយសេចក្តីស្រឡាញ់គឺមានន័យថា យើងបានបំពេញបំណងព្រះហឫទ័យព្រះដែលស្រឡាញ់យើងដូច្នោះដែរ ។

## ៦. សំនួរពិភាក្សា

១. តើជំពូកដែលនិយាយពីសេចក្តីស្រឡាញ់នៅក្នុងព្រះគម្ពីរមួយណា? *១ កូរិនថូស ១៣*

២. តើយើងអាចធ្វើអ្វីបាននៅពេលដែលយើងពិបាកក្នុងការស្រឡាញ់នរណាម្នាក់?

*សូមព្រះយេស៊ូវជួយយើងឲ្យស្រឡាញ់មនុស្សនោះ*

៣. តើព្រះបានបង្ហាញសេចក្តីស្រឡាញ់ពិតរបស់ព្រះអង្គចំពោះយើងដោយរបៀបណា?

*ទ្រង់បានចាត់ព្រះយេស៊ូវជាបុត្ររបស់ទ្រង់ឲ្យសុគតដោយព្រោះអំពើបាបរបស់យើង ហើយទ្រង់រស់ឡើង វិញ ដើម្បីឲ្យយើងបាននៅជាមួយនឹងទ្រង់ជារៀងរហូត*

៤. តើយើងគួរធ្វើអ្វីក្នុងនាមជាមនុស្សទទួលបានក្ដីស្រឡាញ់ពីព្រះជាម្ចាស់?

*យើងត្រូវស្រឡាញ់ព្រះ និងស្រឡាញ់អ្នកដទៃដែរ!*

## ៧. ល្បែងកំសាន្ត «តើអ្វីជាសេចក្ដីស្រឡាញ់?»

**សម្ភារដែលត្រូវការ៖** ខ្មៅដៃ និងបោះពុម្ពព្រះគម្ពីរ **១កូរិនថូស ១៣:៤-៧** (សូមមើលខាងក្រោម)


សូមគូសរង្វង់ពាក្យដែលពណ៌នាអំពីក្ដីស្រឡាញ់៖
១ កូរិនថូស ១៣៖៤-៧
៤ ឯសេចក្ដីស្រឡាញ់តែងតែអត់ធ្មត់ ហើយក៏សប្បុរស សេចក្ដីស្រឡាញ់មិន ចេះឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំផង
៥ មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស
៦ មិនដែលអរសប្បាយចំពោះសេចក្ដី ទុច្ចរិតឡើយ គឺអរសប្បាយតែនឹងសេចក្ដី ស្មោះត្រង់វិញ
៧ ក៏គ្របបាំងទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់

១.ឲ្យកុមារចាប់ដៃគូ ២នាក់ៗ សូមឲ្យក្រដាសថតចំលង **១ កូរិនថូស ១៣:៤-៧** ១ច្បាប់ឲ្យក្រុមនីមួយៗ។

២. ឲ្យពួកគេគូសរង្វង់ពាក្យទាំងអស់ដែលនិយាយអំពីសេចក្ដីស្រឡាញ់។

៣.ប្រហែល ៥នាទីក្រោយមក សូមឱ្យកុមារបំពេញនូវអ្វីដែលគ្រូនិយាយ(គ្រូនឹង ជ្រើសរើសក្រុមដែលលើកដៃមុនគេ។ ក្រុមដែលឆ្លើយបានមុនគេនឹងទទួលបានពិន្ទុ)៖

៤. សេចក្ដីស្រឡាញ់គឺ __________ (អត់ធ្មត់) សេចក្ដីស្រឡាញ់គឺ _________ (សប្បុរស) ។ មិនចេះ _________ (ឈ្នានីស) មិនចេះ ________ (អួតខ្លួន) មិនដែល ________ (មានចិត្តធំ) ។ ៥. មិនចេះ ___________ (ប្រព្រឹត្តបែបមិនគួរសមនឹងអ្នកដទៃ) មិនរក_________ (ប្រយោជន៍ផ្ទាល់ខ្លួន) មិន ___________ (រហ័សខឹង) មិន _________ (ប្រកាន់ទោស) ។ ៦. សេចក្ដីស្រឡាញ់មិន _________ (អរសប្បាយចំពោះសេចក្ដីទុច្ចរិតឡើយ) ប៉ុន្តែអរសប្បាយជាមួយនឹង __________ (សេចក្ដីស្មោះត្រង់ វិញ) ។ ៧. តែងតែ _________ (គ្របបាំងទាំងអស់) តែងតែ __________ (ជឿទាំងអស់) តែងតែ _________ (សង្ឃឹមទាំងអស់) តែងតែ __________ (ទ្រាំទ្រទាំងអស់) ។

៤. សួរកុមារថាតើពាក្យដែលពណ៌នាអំពីសេចក្ដីស្រឡាញ់មួយណាដែលពួកគេចូលចិត្ត ហើយឲ្យពួកគេពន្យល់ថាហេតុអ្វីបានជាគេចូលចិត្តពាក្យនោះ។

## ៨. ខគម្ពីរចងចាំ យ៉ូហាន ១៣:៣៤

## ៩. ហត្ថកម្ម «ផ្កានៃក្ដីស្រឡាញ់»



**សម្ភារៈដែលត្រូវការ៖** បោះពុម្ព "ផ្កានៃក្ដីស្រឡាញ់" (សូមមើលខាងក្រោម) ខ្មៅដៃពណ៌

១. ឲ្យ "ផ្កានៃក្ដីស្រឡាញ់" ដល់កុមារម្នាក់ៗ។

២.ឲ្យកុមារសរសេរពីការពណ៌នាអំពីសេចក្ដីស្រឡាញ់ពី **១កូរិនថូស១៣** (ប្រើច្បាប់ចម្លងដែលបានប្រើក្នុងល្បែង) លើត្របកផ្កា រួចលាបពណ៌ដើម្បីតុបតែង

៣.ពន្យល់ដល់កុមារថាយើងត្រូវតែស្រឡាញ់អ្នកដទៃដោយសារព្រះអង្គទ្រង់ ស្រឡាញ់យើង។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# សូមគូសរង្វង់ពាក្យដែលពណ៌នាអំពីក្តីស្រឡាញ់៖

## ១ កូរិនថូស ១៣:៤-៧

៤ ឯសេចក្តីស្រឡាញ់តែងតែអត់ធ្មត់ ហើយក៏សប្បុរស
សេចក្តីស្រឡាញ់មិនចេះឈ្នានីស មិនចេះអួតខ្លួន
ក៏មិនដែលមានចិត្តធំផង

៥ មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរក
ប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស

៦ មិនដែលអរសប្បាយចំពោះសេចក្តីទុច្ចរិតឡើយ គឺ
អរសប្បាយតែនឹងសេចក្តីស្មោះត្រង់វិញ

៧ ក៏គ្របបាំងទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់
ហើយទ្រាំទ្រទាំងអស់។

# ផ្កានៃក្តីស្រឡាញ់



**យ៉ូហាន ១៣:៣៤** *"ខ្ញុំឲ្យសេចក្ដីបញ្ញត្តិ១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។"*